ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ១២ កយ.សសរ/២៤

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារពិសេសតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់ សាលាដំបូងជ្រះក្តី និងអង្គការអយ្យការអម សាលាដំបូងជ្រះក្តី ចំពោះសំណុំរឿង គ្រឿងញៀន ចរាចរណ៍ និងអន្តរានុក្រូលដ្ឋាន

២០២៤

ក្រសួងយុត្តិធម៌

លេខ : ១៧ កឃ.សសរ/២៤

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារពិសេសតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ចំពោះសំណុំរឿងគ្រឿងញៀន ចរាចរណ៍ និងអគ្រានុកូលដ្ឋាន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## និងជាប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញសេចក្តីសម្រេចលេខ ០១ កឃ.សសរ/២៤ ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈបញ្ជាការដឹកនាំយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១ ..**

បង្កើត **ក្រុមការងារពិសេសតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តី ចំពោះសំណុំរឿងគ្រឿងញៀន ចរាចរណ៍ និងអគ្រានុកូលដ្ឋាន** ដែលសរសេរជាអក្សរកាត់ថា **ក.គ.ច.អ.** ចំណុះឱ្យគណៈបញ្ជាការដឹកនាំយុទ្ធនាការជំរុញនិងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងយុទ្ធនាការត្រួតពិនិត្យនិងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **គឹម សន្តិភាព** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | ប្រធាន |
| ២-ឯកឧត្តម **សុន ពិសិដ្ឋ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣-ឯកឧត្តម **យឹម សារី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៤-ឯកឧត្តម **ជាម សត្យា** | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ | អនុប្រធាន |



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

| | | |
|---|---|---|
| ៥-លោកស្រី **សួរ ដានី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងយុត្តិធម៌ | សមាជិក |
| ៦-លោកស្រី **សារឿន សុពណ៌** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងយុត្តិធម៌ | សមាជិក |
| ៧-លោក **ម៉េង គួច** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន កិច្ចការទោសព្រហ្មទណ្ឌ | សមាជិក |
| ៨-លោកស្រី **សរ ច័ន្ទរ៉ាត** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន កិច្ចការទោសព្រហ្មទណ្ឌ | សមាជិក |
| ៩-លោកស្រី **ផល សុភាព** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន កិច្ចការទោសព្រហ្មទណ្ឌ | សមាជិក |
| ១០-លោក **លាវ ពិសិដ្ឋ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការ អន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ | សមាជិក |
| ១១-លោក **នាង ស៊ីណាវឌ្ឍនៈ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការ អន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ | សមាជិក |
| ១២-លោកស្រី **រាម នាវតី** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៣-លោក **ឃាក វិសាលរតនៈ** | ប្រធាននាយកដ្ឋាន | សមាជិក |
| ១៤-កញ្ញា **ហឿន វណ្ណាស័ន** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៥-លោក **ព្រឹក វឌ្ឍបណ្ឌូល** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៦-លោក **សួង ម៉ុនថា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ១៧-លោក **អ៊ុន សុភាព** | ប្រធានការិយាល័យ | សមាជិក |
| ១៨-លោក **ហេង សុថា** | ប្រធានការិយាល័យ | សមាជិក |
| ១៩-លោក **ពុធ មករា** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ជំនួយការ |
| ២០-កញ្ញា **រឹម រ៉ាណែត** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ជំនួយការ |
| ២១-លោក **ស៊ឹម មករា** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ជំនួយការ |
| ២២-លោក **ឆូ ស៊ីនួន** | មន្ត្រីគ្រប់គ្រងរដ្ឋបាល | ជំនួយការ |
| ២៣-លោក **មៃ វិច្ឆិកា** | មន្ត្រីកម្មសិក្សា | ជំនួយការ |
| ២៤-លោក **គឹម សហាស្សវត្ស** | មន្ត្រីជាប់កិច្ចសន្យា | ជំនួយការ |
| ២៥-កញ្ញា **សេង ប៉ូហ្គេច** | មន្ត្រីជាប់កិច្ចសន្យា | ជំនួយការ។ |

**ក.គ.ច.អ.** មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ជាសេនាធិការប្រតិបត្តិរបស់**គណៈបញ្ជាការដឹកនាំយុទ្ធនាការ** ក្នុងការតាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់របស់សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីនៅគ្រប់ដំណាក់កាលនៃនីតិវិធី ចំពោះសំណុំរឿងពាក់ព័ន្ធនឹងករណីគ្រឿងញៀន ចរាចរណ៍ និងអត្រានុកូលដ្ឋាន
- ពិនិត្យ ផ្តល់យោបល់ និងលើកសំណើវិធានការចំពោះភាពមិនប្រក្រតីនៃចំណាត់ការរបស់តុលាការចំពោះសំណុំរឿងគ្រឿងញៀន ចរាចរណ៍ និងអត្រានុកូលដ្ឋាន ដែលត្រូវបានរកឃើញ

- សម្របសម្រួលការងារ និងសហការជាមួយសាលាជម្រះក្តី និងស្ថាប័នពាក់ព័ន្ធ ក្នុងក្របខ័ណ្ឌការងារដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាដល់ប្រសិទ្ធភាពនៃការអនុវត្តការងារ
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការងាររបស់ខ្លួន និងលើកសំណើវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម ជូនប្រធាន**គណៈបញ្ជាការដឹកនាំយុទ្ធនាការ** ពិនិត្យ និងសម្រេច
- អនុវត្តភារកិច្ចផ្សេងទៀត តាមការប្រគល់ពីប្រធាន**គណៈបញ្ជាការដឹកនាំយុទ្ធនាការ**។

**ប្រការ២ .-**

លេខាធិការដ្ឋាន នៃ**គណៈបញ្ជាការដឹកនាំយុទ្ធនាការ** ត្រូវសហការផ្តល់ទិន្នន័យនៃសំណុំរឿងគ្រឿងញៀន ចរាចរណ៍ និងអត្រានុកូលដ្ឋាននៅតាមតុលាការ ព្រមទាំងព័ត៌មាន និងការគាំទ្រចាំបាច់នានា ដល់ **ក.គ.ច.អ.** ដើម្បីឱ្យ **ក.គ.ច.អ.** អាចអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនបានប្រកបដោយប្រសិទ្ធភាព។

**ប្រការ៣ .-**

អនុប្រធាន និងសមាជិកនៃ **ក.គ.ច.អ.** ត្រូវចូលរួមក្នុងកិច្ចប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន ឬមានធុរៈ អនុប្រធាន អាចកោះប្រជុំ និង/ឬ ដឹកនាំកិច្ចប្រជុំជំនួសតាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់យន្តការចំណុះ**គណៈបញ្ជាការដឹកនាំយុទ្ធនាការ** ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៤ រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**
**និងជាប្រធានគណៈបញ្ជាការដឹកនាំយុទ្ធនាការ**

កើត រិទ្ធ

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- សាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ